**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **ក្រសួងពាណិជ្ជកម្ម**

**លេខ** ...............០០៥/២២..............**ក.ប** / ស.ណ.ណ.ខ.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាលើវិស័យនាំចេញវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរនិងកាបូប

យោងអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការអន្តរជាតិខាងការងារ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា, ប្រកាសអន្តរក្រសួងលេខ ៣៦៤/២០ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ស្តីពីការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាលើវិស័យនាំចេញវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរនិងកាបូប, ប្រកាសលេខ២៣២ ព.ណបអព.ប្រក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទចុះបញ្ជីទទួលសិទ្ធិនាំចេញទំនិញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងសេចក្តីណែនាំលេខ០២១/២១ កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការអនុវត្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាលើវិស័យនាំចេញវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរនិងកាបូប ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម សូមក្រើនរំលឹកដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ដែលផលិត និងនាំចេញផលិតផលវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរនិងកាបូបទាំងអស់ដូចខាងក្រោម៖

១. ត្រូវចុះបញ្ជី និងបង់វិភាគទានហិរញ្ញវត្ថុទ្រទ្រង់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (Better Factories Cambodia – BFC) តាមរយៈសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (Garment Manufacturers Association in Cambodia – GMAC) ស្របតាមស្មារតីនៃអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការអន្តរជាតិខាងការងារ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

២. ត្រូវមានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ ដែលចេញដោយគណៈកម្មការផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបញ្ជាក់អំពីស្ថានភាពលក្ខខណ្ឌការងារប្រចាំរោងចក្រ សហគ្រាស ស្របតាមប្រកាសលេខ៤៣៤/២០ ក.ប/ប្រ.ក.ខ.ល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ។ សម្រាប់ឆ្នាំ២០២២ នេះ រោងចក្រ សហគ្រាសអាចស្នើសុំវិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ប្រចាំឆ្នាំ២០២២ ក្នុងរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម តាមរយៈគេហទំព័រ https://sicms.mlvt.gov.kh/ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

៣. ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២២ តទៅ រោងចក្រ សហគ្រាស ដែលផលិត និងនាំចេញផលិតផលវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរនិងកាបូប ដែលមិនបានចុះបញ្ជី និងបង់វិភាគទានហិរញ្ញវត្ថុទ្រទ្រង់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា និងមិនមានវិញ្ញាបនបត្របញ្ជាក់អនុលោមភាពលក្ខខណ្ឌការងារប្រចាំឆ្នាំដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងមិនទទួលបានសិទ្ធិក្នុងការនាំចេញទំនិញទៅបរទេសពីក្រសួងពាណិជ្ជកម្មឡើយ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់ ឬនាយករោងចក្រ សហគ្រាស ព្រមទាំងការិយភារីនៃវិស័យនាំចេញវាយនភណ្ឌ និងកាត់ដេរសម្លៀកបំពាក់ និងផលិតផលធ្វើដំណើរនិងកាបូបទាំងអស់ ចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ៥ កើត ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០២២

| | |
|---|---|
| រដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្រសួងពាណិជ្ជកម្ម |
| អ៊ិត សំហេង | ប៉ាន សូរស័ក្តិ |